ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

***************

សាលាឧទ្ធរណ៍ភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ១៤៩ / ១៣.០២.២០១៣

សាលដីកា

លេខ:១០៤ ក្រ.III.ស/២៦.១២.២០១៣

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៣ ដោយមានសមាសភាពដូចតទៅ:

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ជាប្រធាន

លោក [redacted] ជាចៅក្រមប្រឹក្សា

លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជី**

កញ្ញា [redacted]

ដើម្បីធ្វើការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ នៃសំណុំរឿងព្រហ្មទណ្ឌលេខ ១៤៩ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៣ រវាង ៖

ជនជាប់ចោទឈ្មោះ [redacted] ឌីឆាំ ភេទប្រុស អាយុ៤០ឆ្នាំ ជាតិខ្មែរ មុខរបរៈបុគ្គលិកក្រុមហ៊ុន Win World Trading Co LTD ទីកន្លែងកំណើត សង្កាត់លេខ១ ក្រុងភ្នំពេញ [redacted] ផ្លូវជាតិលេខ១៣ ភូមិសួនសុវណ្ណ ខណ្ឌប៉ាកសេ ខេត្តចំប៉ាសាក់ ប្រទេសឡាវ មានទីលំនៅមុនចាប់ខ្លួន ភូមិរាជានុកូល ឃុំស្ទឹងត្រែង ស្រុកស្ទឹងត្រែង ខេត្តស្ទឹងត្រែង ឪពុកឈ្មោ[redacted] ម្តាយឈ្មោះ[redacted](ស) នៅលីវ ទោសពីមុនគ្មាន ឃុំខ្លួនថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១២។

ជាប់ចោទពីបទ: រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅចំណុចផ្ទះលេខ៧៦ ផ្លូវកម្ពុជាក្រោម សង្កាត់ផ្សារថ្មីទី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីអំឡុងខែមិថុនា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុវណ្ណ ភេទប្រុស អាយុ៥១ឆ្នាំ ជាតិខ្មែរ មុខរបរៈនាយកក្រុមហ៊ុន Win World Trading CoLTD បច្ចុប្បន្នរស់នៅផ្ទះលេខ៧៦ ផ្លូវលេខ២២៦ សង្កាត់ផ្សារថ្មីទី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។



Scanned with CamScanner

**ឯដំណើររឿងមានដូចតទៅ ៖**

កាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ ជនរងគ្រោះឈ្មោះ [redacted] សុវណ្ណ បានបើកក្រុមហ៊ុន Win World Trading Co LTD ដែលមានទីតាំងស្ថិតនៅផ្ទះលេខ៧៦ ផ្លូវកម្ពុជាក្រោម សង្កាត់ផ្សារថ្មីទី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ដោយមានជនជាប់ចោទឈ្មោះ [redacted] ឌីឆាំ ជាសមាជិកភាគហ៊ុនទៀតផង។ បន្ទាប់មក ជនរងគ្រោះឈ្មោះ [redacted] សុវណ្ណ បានប្រគល់ប្រាក់ចំនួនដប់ប្រាំពីរម៉ឺនដុល្លាអាមេរិក ឲ្យទៅជនជាប់ចោទឈ្មោះ [redacted] ឌីឆាំ ដើម្បីយកទៅទិញឈើក្រញូង បានចំនួន១៣ម$^{៣}$ ដោយយកទៅរក្សាទុកក្នុងឃ្លាំងឯប្រទេសឡាវ ហើយជនរងគ្រោះឈ្មោះ [redacted] សុវណ្ណ បានឲ្យជនជាប់ចោទឈ្មោះ [redacted] ឌីឆាំ ជាអ្នកមើលការខុសត្រូវជំនួស។ បន្ទាប់មក ជនរងគ្រោះឈ្មោះ [redacted] សុវណ្ណ បាននាំម៉ូយទៅមើលឈើក្រញូងរបស់ខ្លួនដែលបានរក្សាទុកក្នុងឃ្លាំងប្រទេសឡាវ ស្រាប់តែបាត់ឈើក្រញូងទាំងនោះអស់។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៣៥ «ប» ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:

១- ផ្តន្ទាទោសលើឈ្មោះ [redacted] ឌីឆាំ ភេទប្រុស អាយុ៤០ឆ្នាំ ដាក់ពន្ធនាគារកំណត់ ១៦ (ដប់ប្រាំមួយ) ខែ និងពិន័យជាប្រាក់ចំនួន ២.០០០.០០០(ពីរលាន)រៀល។

ពីបទ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅ ចំណុចផ្ទះលេខ៧៦ ផ្លូវកម្ពុជាក្រោម សង្កាត់ផ្សារថ្មីទី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីអំឡុងខែមិថុនា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមមាត្រា ៣៩២ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

២- បង្គាប់ឲ្យឈ្មោះ [redacted] ឌីឆាំ សងសំណងការខូចខាតចំនួន ១៧០.០០០ (ដប់ប្រាំពីរម៉ឺន) ដុល្លាអាមេរិក និងសំណងជម្ងឺចិត្តចំនួន ១០.០០០.០០០(ដប់លាន)រៀល ឲ្យទៅឈ្មោះ [redacted] សុវណ្ណ។ ការទាមទារលើសពីនេះបដិសេធចោល តាមមាត្រា២៣និងមាត្រា៣៥៥ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

៣. សាលក្រមនេះ ជំនុំជម្រះ នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១២ ចំពោះមុខជនជាប់ចោទ និងចំពោះមុខមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី, បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

បានឃើញបណ្តឹងឧទ្ធរណ៍ លេខ ៥៨៩ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] ឌីឆាំ ជាជនជាប់ចោទ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៣៥ «ប» ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

បានឃើញ របាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍ ។៚



Scanned with CamScanner

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សា បញ្ជាក់អង្គហេតុរឿងជូនអង្គសវនាការ

ក្រឡាបញ្ជីអានចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted]សុវណ្ណ ឆ្លើយនៅសាលាដំបូងរាជធានីភ្នំពេញ។

ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ [redacted]លីហ៊ាន់ ឆ្លើយនៅសាលាដំបូងរាជធានីភ្នំពេញ។

ក្រឡាបញ្ជីអានចម្លើយសាក្សី [redacted] សំអាង ឆ្លើយនៅសាលាដំបូងរាជធានីភ្នំពេញ។

ជនជាប់ចោទឈ្មោះ [redacted]ឌីឆាំ ឆ្លើយថា ខ្លួនគ្រាន់តែជាអ្នកបកប្រែភាសាឲ្យក្រុមហ៊ុន ឈ្មោះ Win World Trading ដែលមានឈ្មោះ[redacted]សុវណ្ណ ជាប្រធានប៉ុណ្ណោះ, ខ្លួនពុំមែនជាសមាជិកក្រុមហ៊ុនទេ ហើយក៏គ្មានភាគហ៊ុនទៀតផង តែខ្លួនពិតជាបានចុះហត្ថលេខាក្នុងលក្ខន្តិកៈក្រុមហ៊ុន និងបានដាក់ឈ្មោះជាសមាជិកក្រុមហ៊ុន Win World Trading នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១១ មែន។ ខ្លួនពុំមែនជាអ្នកមើលថែរក្សាឈើទេ គឺមានឈ្មោះ[redacted]សំអាង និងឈ្មោះ[redacted]សុខនី ជាអ្នកយាមឃ្លាំង និងមើលការខុសត្រូវ។

## សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

បណ្ដឹងឧទ្ធរណ៍របស់ជនជាប់ចោទឈ្មោះ[redacted]ឌីឆាំ ធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ យោងតាមមាត្រា៣៧៥ និងមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, ជនជាប់ចោទបានឆ្លើយបដិសេធថា មិនបានប្រព្រឹត្ត តែខ្លួនបានចុះហត្ថលេខាលើលិខិតរបស់ក្រុមហ៊ុនពិតមែន, ដោយមានចម្លើយរបស់ឈ្មោះ[redacted] សំអាង និងឈ្មោះ [redacted] លីហ៊ាន់ ឆ្លើយដាក់បន្ទុកលើជនជាប់ចោទ។ រឿងនេះជារឿងជួញដូរឈើក្រញូង ជាអំពើខុសច្បាប់ សូមក្រុមប្រឹក្សាពិនិត្យ និង ពិចារណាតាមច្បាប់។

ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ

ក្រោយពីបានស្ដាប់អំណានចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី

ក្រោយពីបានស្ដាប់អំណានចម្លើយសាក្សី

ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់

## សភាព្រហ្មទណ្ឌ យល់ឃើញថា:

១. បណ្ដឹងឧទ្ធរណ៍លេខ ៥៨៩ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១២ របស់ឈ្មោះ[redacted]ឌីឆាំ ជាជនជាប់ចោទ ធ្វើក្នុងកំណត់ច្បាប់ តាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២. តាមចម្លើយជនជាប់ចោទថា ខ្លួនគ្រាន់តែជាអ្នកបកប្រែភាសាឲ្យក្រុមហ៊ុន ឈ្មោះ Win World Trading ដែលមានឈ្មោះ [redacted] សុវណ្ណ ជាប្រធានប៉ុណ្ណោះ, ខ្លួនពុំមែនជាសមាជិកក្រុមហ៊ុនទេ ហើយក៏គ្មានភាគហ៊ុនទៀតផង តែខ្លួនពិតជាបានចុះហត្ថលេខាក្នុងលក្ខន្តិកៈក្រុមហ៊ុន និងបានដាក់ឈ្មោះជាសមាជិកក្រុមហ៊ុន Win World Trading នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១១ មែន។ ខ្លួនពុំមែនជាអ្នកមើលថែរក្សាឈើទេ គឺមានឈ្មោះ [redacted]សំអាង និងឈ្មោះ[redacted] សុខនី ជាអ្នកយាមឃ្លាំង និងមើលការខុសត្រូវ។



Scanned with CamScanner

៣. តាមចម្លើយសាក្សីឈ្មោះ [redacted] លីវ៉ាន់ និងឈ្មោះ [redacted] សំអាង ថា ឈ្មោះ [redacted] ឌីឆាំ ជាអ្នកទទួលប្រាក់ពីឈ្មោះ [redacted] សុវណ្ណ យកទៅទិញឈើក្រញូងនៅប្រទេសឡាវ, ឈ្មោះនេះជាសមាជិកភាគហ៊ុន និងជាអ្នកមានភារៈដើរប្រមូលទិញឈើក្រញូង។ ឈ្មោះ [redacted] ឌីឆាំ ពិតជាបានយកឈើចំនួន១៤ម$^{៣}$ របស់ក្រុមហ៊ុនទៅលក់មែន, ករណីនេះ ឈ្មោះ [redacted] ឌីឆាំ បានប្រាប់ខ្លួនថា ខ្លួនគេបានលក់ឈើក្រុមហ៊ុនអស់ហើយ និងយកប្រាក់នេះទៀតផង។

៤. មានភស្តុតាងដាក់បន្ទុកលើជនជាប់ចោទ ពីបទ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅចំណុចផ្ទះលេខ ៧៦ ផ្លូវកម្ពុជាក្រោម សង្កាត់ផ្សារថ្មីទី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីអំឡុងខែមិថុនា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។

៥. សាលក្រមព្រហ្មទណ្ឌលេខ ៣៥ «ប» ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចត្រឹមត្រូវ គួរតម្កល់ទុកជាបានការ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១. ទទួលបណ្តឹងឧទ្ធរណ៍ ៥៨៩ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] ឌីឆាំ ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២. តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៣៥ «ប» ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការទាំងមូល។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៣ ប្រកាសជាសាធារណៈ នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៣ ចំពោះមុខជនជាប់ចោទ, បើកផ្លូវសាទុក្ខ០១ខែ គិតចាប់ពីថ្ងៃប្រកាសសាលដីកានេះ។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះ ឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted], [redacted] | ហត្ថលេខា: [redacted] |

បានឃើញ
ប្រធានសាលាឧទ្ធរណ៍

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ, ថ្ងៃទី ០៤ ខែ ៦ ឆ្នាំ ២០១៤
ក្រឡាបញ្ជី



Scanned with CamScanner